# សាក្សីងាយរងគ្រោះ និងការជជីកសួរមុនពេលកាត់ក្តី

ចៅក្រម Martin Picton

# គណៈកម្មាធិការប្រឹក្សាស្តីពីភ័ស្តុតាងវីដេអូ (របាយការណ៍ Pigot) ឆ្នាំ ១៩៨៨

បានស្នើឡើងថាភ័ស្តុតាងទាំងស្រុងរបស់កុមារ រួមទាំងការជជីកសួរ គប្បីត្រូវធ្វើនៅក្រៅតុលាការ និងមុនការកាត់ក្តី

# “ការនិយាយដោយចំហដើម្បីយុត្តិធម៌” ឆ្នាំ ១៩៩៨

- របាយការណ៍របស់ក្រុមការងារអន្តរនាយកដ្ឋាននៃក្រសួងមហាផ្ទៃស្តីពីប្រព្រឹត្តិកម្មចំពោះសាក្សីងាយរងគ្រោះ ឬដែលរងការបំភិតបំភ័យនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ
- បានផ្តល់អនុសាសន៍ថា គេគប្បីមានវិធានការពិសេស ដើម្បីជួយឱ្យសាក្សីងាយរងគ្រោះ ឬដែលរងការបំភិតបំភ័យនៅក្នុងការកាត់ក្តីព្រហ្មទណ្ឌអាចផ្តល់ភ័ស្តុតាងល្អបំផុតរបស់ពួកគេ

# យុត្តិធម៌យុវជន និង ភ័ស្តុតាងព្រហ្មទណ្ឌ ឆ្នាំ ១៩៨៩

- ត្រូវបានដាក់ឱ្យប្រើដើម្បីសម្រួលលទ្ធភាពរបស់សាក្សីងាយរងគ្រោះ និង/ឬដែលរងការបំភិតបំភ័យ ក្នុងការផ្តល់ភ័ស្តុតាងប្រកបដោយប្រសិទ្ធភាព និងប្រកបដោយសុវត្ថិភាពក្នុងដំណើរការតុលាការព្រហ្មទណ្ឌ
- ចែងពី "វិធានការពិសេស" មួយចំនួនដែលត្រូវបានរៀបចំឡើងដើម្បីជួយឱ្យសាក្សីអាចផ្តល់ភ័ស្តុតាងល្អបំផុតរបស់ពួកគេ ប៉ុន្តែ ទន្ទឹមនឹងនេះដកពួកគេចេញពីភាពតានតឹងអារម្មណ៍ និងសម្ពាធនៃដំណើរការតុលាការបើកចំហ

# វិធានការពិសេស

- វ.២៣ - អេក្រង់
- វ.២៤ - តំណភ្ជាប់បន្តផ្ទាល់
- វ.២៥ - ភ័ស្តុតាងក្នុងលក្ខណៈសម្ងាត់
- វ.២៦ - ការដោះសក់ពាក់ និងអាវវែង (សម្រាប់ចៅក្រម)

# វិធានការ ពិសេស

- វ.២៧ - ភ័ស្តុតាងសាក្សីដែលថតទុកជាវីអូ
- វ.២៨ - ការជជីកសួរដែលថតទុកទុកជាមុន
- វ.២៩ - អន្តរការី
- វ.៣០ - សម្ភារជំនួយសម្រាប់ទំនាក់ទំនង

- អាយុក្រោម ១៨ ឆ្នាំ និង/ឬ
- មានបញ្ហាផ្លូវចិត្ត ឬពិការភាពផ្នែកសិក្សា និង/ឬ
- មានជំងឺឬពិការភាពរាងកាយ និង/ឬ
- បុគ្គលដែលងាយទទួលរងការភ័យខ្លាច ឬទុក្ខព្រួយក្នុងការផ្តល់ភ័ស្តុតាង ដោយសារកាលៈទេសៈផ្ទាល់ខ្លួន ឬអ្នកដែលទាក់ទងនឹងករណី
- តុលាការត្រូវតែគិតគូរជានិច្ចអំពីទស្សនៈទាំងឡាយដែលបង្ហាញដោយសាក្សី

# សិទ្ធិ

- ជនដាក់បណ្ដឹងទាក់ទងនឹងបទល្មើសផ្លូវភេទ បទល្មើសនៅក្រោមផ្នែកទី ១ ឬ ២ នៃច្បាប់ទាសភាពសម័យទំនើប ឆ្នាំ ២០១៥ និងជនដែលអាចជារងគ្រោះនៃការបំពានក្នុងគ្រួសារ មានសិទ្ធិទទួលបានជំនួយដោយស្វ័យប្រវត្តិ ប្រសិនបើសាក្សីមិនបានជូនដំណឹងដល់តុលាការអំពីបំណងមិនចង់ទទួលសិទ្ធិនេះ
- សាក្សីទាក់ទងនឹងបទល្មើសដែលមានរាយក្នុង Sch ៩A ក៏មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដោយស្វ័យប្រវត្តិផងដែរ – រួមមានសាច់ញាតិជិតស្និទ្ធដែលកាន់មរណទុក្ខដោយអំពើឧក្រិដ្ឋ ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ឧក្រិដ្ឋកម្មដោយការការរើសអើង ភេរវកម្ម បទល្មើសផ្លូវភេទ ការជួញដូរមនុស្ស ការប៉ុនប៉ងមនុស្សឃាត ការចាប់ជំរិត និងការឃុំឃាំងដោយខុសច្បាប់ ការដុតក្នុងចេតនាបង្កគ្រោះថ្នាក់ដល់ជីវិត និងការធ្វើឱ្យរបួស ឬការបង្កអន្តរាយធ្ងន់ធ្ងរដល់រាងកាយដោយចេតនា

# សិទ្ធិ

# វិធានការពិសេស

- S.១៧ YJCE ១៩៩៩ – **ការភ័យខ្លាច ឬទុក្ខព្រួយ**
- តុលាការត្រូវទទួលយកបានថា គុណភាពនៃភ័ស្តុតាងដែលផ្ដល់ដោយសាក្សីទំនងជាត្រូវបានកាត់បន្ថយដោយហេតុផលនៃការភ័យខ្លាច ឬទុក្ខព្រួយរបស់សាក្សីទាក់ទងនឹងការផ្ដល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការនីតិវិធី
- តុលាការត្រូវគិតគូរជាពិសេស ចំពោះ
  - ប្រភេទ និងកាលៈទេសៈនៃបទល្មើស ដែលទាក់ទងនឹងកិច្ចដំណើរការនីតិវិធី
  - អាយុរបស់សាក្សី
  - ចំណុចខាងក្រោមដែលហាក់បីដូចជាមានភាពពាក់ព័ន្ធចំពោះតុលាការ ពោលគឺ៖

# វិធានការពិសេស

- សាវតារសង្គម និងវប្បធម៌ និងដើមកំណើតជាតិពន្ធុរបស់សាក្សី
- កាលៈទេសៈគ្រួសារ និងការងាររបស់សាក្សី និង
- ជំនឿសាសនា ឬមតិនយោបាយរបស់សាក្សី;
- អាកប្បកិរិយាណាមួយចំពោះសាក្សី ដោយ
  - (i) ជនជាប់ចោទ
  - (ii) សមាជិកគ្រួសារ ឬសហការីរបស់ជនជាប់ចោទ ឬ
  - (iii) ជនផ្សេងទៀតដែលទំនងគឺជាជនជាប់ចោទម្នាក់ ឬជាសាក្សីម្នាក់ក្នុងកិច្ចដំណើរការនីតិវិធី។

# វិធានការពិសេស

- ប្រភេទនិងកាលៈទេសៈនៃបទល្មើសដែលកិច្ចដំណើរការពាក់ព័ន្ធ
- អាយុរបស់សាក្សី
- បញ្ហាដែលហាក់បីដូចជាមានការពាក់ព័ន្ធចំពោះតុលាការ ពោលគឺ៖
  - (i) សាវតាសង្គម និងវប្បធម៌ និងដើមកំណើតជាតិពន្ធុរបស់សាក្សី
  - (ii) កាលៈទេសៈគ្រួសារនិងការងាររបស់សាក្សី និង
  - (iii) ជំនឿសាសនា ឬមតិនយោបាយរបស់សាក្សី។

# វិធានការពិសេស

- (ឃ) អាកប្បកិរិយាណាមួយចំពោះសាក្សី ដោយ

(i) ជនជាប់ចោទ

(ii) សមាជិកគ្រួសារ ឬសហការីរបស់ជនជាប់ចោទ ឬ

(iii) ជនផ្សេងទៀតដែលទំនងគឺជាជនជាប់ចោទម្នាក់ ឬជាសាក្សីម្នាក់ក្នុងកិច្ចដំណើរការនីតិវិធី។

# ៤១៦ និង ១៧ ត្រូវអនុវត្តនៅក្នុងបរិបទនៃ ៤១៩, ២០ និង ២១

- (២) ពេលដែលតុលាការសម្រេចថាសាក្សីមានសិទ្ធិ នោះតុលាការត្រូវ
  - (ក) កំណត់ថាតើវិធានការពិសេសណាមួយដែលទាក់ទងនឹងសាក្សី (ឬការរួមបញ្ចូលគ្នាណាមួយនៃវិធានការទាំងនោះ) តាមយោបល់របស់តុលាការទំនងជានឹងធ្វើឱ្យមានភាពប្រសើរឡើងនូវគុណភាពនៃភស្តុតាងដែលផ្តល់ដោយសាក្សី និង

# ៦១៦ និង ១៧ ត្រូវអនុវត្តនៅក្នុងបរិបទនៃ ៦១៨, ២០ និង ២១

(ខ) ប្រសិនបើអញ្ជឹងមែន

(i) កំណត់ថាវិធានការណាមួយ (ឬការរួមបញ្ចូលគ្នានៃវិធានការទាំងនោះ) តាមយោបល់របស់តុលាការទំនងជាអាចបង្កើនតាមដែលអាចធ្វើទៅបាននូវគុណភាពភ័ស្តុតាង និង

(ii) ផ្តល់ការណែនាំមួយនៅក្រោមផ្នែកនេះ ដែលចែងពីវិធានការ ដែលត្រូវបានកំណត់ថាដូច្នេះ ដើម្បីអនុវត្តចំពោះភ័ស្តុតាងដែលបានផ្តល់ដោយសាក្សី។

# វិធាន ១៦ និង ១៧ ត្រូវអនុវត្តនៅក្នុងបរិបទនៃ វិធាន ១៩, ២០ និង ២១

- (៣) ក្នុងការកំណត់ថា ... តើវិធានការពិសេសណាមួយទំនងជានឹងធ្វើឱ្យប្រសើរ ឬមិនប្រសើរឡើង ឬបង្កើនឡើង តាមដែលធ្វើទៅបាន នូវគុណភាពនៃភស្តុតាងដែលផ្តល់ដោយសាក្សី តុលាការត្រូវតែពិចារណាគ្រប់កាលៈទេសៈទាំងអស់នៃសំណុំរឿង រួមមាន ជាពិសេសៈ

  (ក) ទស្សនៈណាមួយដែលបង្ហាញដោយសាក្សី និង

  (ខ) ថាតើវិធានការអាចទំនងជារារាំងដល់ភស្តុតាង ដែលត្រូវបានសាកល្បងប្រកបដោយប្រសិទ្ធភាពដោយភាគីមួយនៃនៃកិច្ចដំណើរការនីតិវិធី។

- (៣) វិធានចម្បងនៅក្នុងករណីសាក្សីជាកុមារ គឺថាតុលាការត្រូវផ្តល់ការណែនាំអំពីវិធានការពិសេសទាក់ទងនឹងសាក្សីដែលអនុលោមតាមលក្ខខណ្ឌដូចខាងក្រោម៖

  (ក) វិធាននេះត្រូវចែងពីការកត់ត្រាពាក់ព័ន្ធដែលត្រូវទទួលយក អនុលោមតាមផ្នែកទី ២៧ (ភស្តុតាងសាក្សីដែលថតទុកជាវីដេអូ) និង

  (ខ) វិធាននេះត្រូវចែងពីភស្តុតាងដែលផ្តល់ដោយសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធី ដែលភស្តុតាងនោះមិនត្រូវបានផ្តល់ដោយមធ្យោបាយនៃការថតទុកវីដេអូ (ទោះជាភស្តុតាងសាក្សី ឬមិនមែនក្តី) ដែលត្រូវផ្តល់តាមរយៈតំណភ្ជាប់បន្តផ្ទាល់ស្របតាមផ្នែកទី ២៤។

## S.២១ - បទប្បញ្ញត្តិពិសេសទាក់ទិននឹងសាក្សីជាកុមារ

# ស.២៨ ការជជីកសួរដែលបានថតទុកជាមុន

- បានចំណាយពេលយូរដើម្បីឈានដល់ដំណាក់កាលនៃការអនុវត្ត
- មិនបានអនុវត្ត រហូតដល់ឆ្នាំ ២០១៣ - តុលាការសាកល្បង
- ផ្សព្វផ្សាយថ្នាក់ជាតិសម្រាប់សាក្សីវ័យក្មេង និងងាយរងគ្រោះ (ស.១៦) ឥឡូវនេះបានបញ្ចប់ហើយ
- ផ្សព្វផ្សាយជាដំណាក់កាលសម្រាប់សាក្សីដែលត្រូវគេបំភិតបំភ័យ (ស.១៧) ឥឡូវនេះកំពុងដំណើរការ
- រាប់បញ្ចូលទាំងអ្នកដាក់បណ្ដឹងនៅក្នុងករណីនៃបទល្មើសផ្លូវភេទ ការបំពានក្នុងគ្រួសារ និងការជួញដូរមនុស្ស
- ស.២៨ ជាជម្រើសត្រឹមត្រូវ ប្រសិនបើវាកែលម្អនិងបង្កើនគុណភាពនៃភ័ស្តុតាង
- សក្តានុពលសម្រាប់សវនាការស្តីពីវិធានដំណើរការនីតិវិធី (GRH) គប្បីត្រូវបានពិចារណា

# ទ.២៨ ការជជីកសួរដែលបានថតទុកជាមុន

- បុព្វលក្ខខណ្ឌចាំបាច់ដែលប៉ូលិសត្រូវឱ្យគេថតទុកវីដេអូនៃការនិយាយរៀបរាប់ពីសាក្សី
- ចាំបាច់ត្រូវកំណត់ការមានសិទ្ធិតាំងពីដំណាក់កាលដំបូង
- គេត្រូវជូនដំណឹងដល់តុលាការ
- ដំណើរការនៃការដាក់ភ័ស្តុតាង និងការបញ្ចេញព័ត៌មានចាំបាច់មុនពេលជំនុំជម្រះ ត្រូវបានពន្លឿន
- ពិចារណាពីតម្រូវការសវនាការស្តីពីវិធានដំណើរការនីតិវិធី (GRH)
- រាយបញ្ជីសំណុំរឿងសម្រាប់សវនាការ ទ.២៨ និងកំណត់កាលបរិច្ឆេទសម្រាប់ការជំនុំជម្រះនៅពេលបន្ទាប់ ក្នុងពេលតែមួយ
- សវនាការ ទ.២៨ គឺជា**ការចាប់ផ្តើម**នៃការជំនុំជម្រះ

# S.២៨ ការជជីកសួរដែលបានថតទុកជាមុន

- តម្រូវឱ្យមេធាវីមើលកញ្ចប់ឧបករណ៍ Advocate’s Gateway - Advocates Gateway
- ទម្រង់ GRH - មេធាវីអាចត្រូវបានតម្រូវឱ្យសរសេរសំណួរជាមុន
- ចៅក្រមគប្បីកត់ត្រាចម្លើយចំពោះសំណួរដែលបានយល់ព្រមនៅក្នុងសវនាការ S.២៨
- ការជជីកសួរដែលបានថតទុកជាមុន - ត្រូវរក្សាទុក និងគ្រប់គ្រងដោយ Vodaphone
- សង្គតិភាពនៃចៅក្រម និងមេធាវី - មិនមែនជាកាតព្វកិច្ចទេ ប៉ុន្តែអាចជាការចង់បាន
- តើការថតទុកចាំបាច់ត្រូវកែសម្រួលឬទេ?
- ចុះបើមេធាវីចង់សួរសំណួរបន្ថែមក្រោយពេលសវនាការ S.២៨?

# សវនាការ ស្តីពីវិធាន ដំណើរការ នីតិវិធី (GRH)

- ក្នុងករណីណាដែលមានសាក្សី ឬ ជនជាប់ចោទដែលជាជនងាយរងគ្រោះ ត្រូវពិចារណាក្នុងការបើកសវនាការលើច្បាប់ជាមូលដ្ឋាន
- កម្រិតនៃភាពងាយរងគ្រោះកាន់តែធ្ងន់ធ្ងរ នោះកាន់តែមានសារៈសំខាន់ក្នុងការរៀបចំសវនាការ

# ការកែសម្រួលដើម្បីភាពងាយរងគ្រោះ

- តើពេលណាគួរហៅសាក្សី?
- តើមេធាវី និងចៅក្រមគួរស្លៀកពាក់បែបណា?
- តើគួរជួបសាក្សីជាមុនឬទេ?
- សម្រាកនៅពេលចាំបាច់
- របៀបគ្រប់គ្រងអន្តរការី
- តម្រូវឱ្យមេធាវីដាក់សំណួរជាមុន – Dinc [២០១៧] EWCA Crim ១២០៦ – មិនត្រឹមតែពាក់ព័ន្ធនឹង S.២៨ ប៉ុណ្ណោះទេ
- កាតព្វកិច្ចគ្រប់គ្រងការសាកសួរសាក្សី, ត្រូវកំណត់ព្រំដែនពេលវេលាសមរម្យ និងត្រូវបង្អាក់ការសួរសំណួរមិនសមរម្យ *Lubemba* [២០១៤] EWCA Crim ២០៦៤

# ការកែសម្រួលដើម្បីភាពងាយរងគ្រោះ

- អនុវត្តការគ្រប់គ្រងការផ្សាយព័ត៌មាន
- សួរសំណួរ, មិនត្រូវផ្តល់យោបល់
- កំណត់ពេលវេលាសម្រាប់ការជជីកសួរ? កំណត់ជាមុន មិនមែននៅពាក់កណ្តាលការជជីកសួរទេ!
- ប្រសិនបើជនជាប់ចោទលើសពីម្នាក់ ចូរបញ្ឈប់មេធាវីទាំងពីរនាក់ដែលបកស្រាយមូលហេតុដូចគ្នា?
- សម្រាប់សាក្សីវ័យក្មេងឬងាយរងគ្រោះ តើករណីnV ចាំបាច់ត្រូវ " មានអំណះអំណាង" ដែរឬទេ?
- ប្រសិនបើរចនាបទ និងខ្លឹមសារនៃសំណួរមានកម្រិត នោះត្រូវគិតថាតើសំណួរអ្វីខ្លះគប្បីត្រូវបានសួរ
- មិនចាំបាច់លើកឡើងនូវអសង្គតិភាពទេ - ចូរបង្ហាញតាមរបៀបផ្សេង

# ចុងចោទងាយរងគ្រោះ

- YJCEA ១៩៩៩ មិនអនុវត្តចំពោះចុងចោទទេ
- តុលាការយុវជន *R. (D) v Camberwell Green Youth Court;* [២០០៥] UKHL ៤ - តុលាការមានអំណាចធំទូលាយ និងអាចបត់បែនបាន ដើម្បីធានាថាចុងចោទបានទទួលការកាត់ក្តីដោយយុត្តិធម៌ រួមទាំងឱកាសសមរម្យក្នុងការផ្តល់ភ័ស្តុតាងប្រសើរបំផុតដែលអាចធ្វើទៅបាន។
- *"ចៅក្រមមានអំណាចក្នុងការចាត់វិធានការដើម្បីធានាឱ្យបាននូវការចូលរួមរបស់ចុងចោទក្នុងដំណើរការជំនុំជម្រះ។ អំណាចរបស់តុលាការគ្មានដែនកំណត់ទេ ទាក់ទិននឹងការធានាការចូលរួមរបស់ជនជាប់ចោទនៅក្នុងការជំនុំជម្រះរបស់ខ្លួន"*។

# ចុងចោទងាយរងគ្រោះ

- SH [២០០៣] EWCA Crim ១២០៨ សាលាឧទ្ធរណ៍បានបង្ហាញមតិថាចៅក្រមជំនុំជម្រះមានឆន្ទានុសិទ្ធិចំពោះវិធានការដែលត្រូវធ្វើដើម្បីជួយចុងចោទដែលមានការលំបាកផ្នែកសិក្សា ហើយវិធានការនេះ នឹងអនុវត្តចំពោះ៖
  - ការអនុញ្ញាតឱ្យគាត់មានជំនួយពីអន្តរការីខណៈពេលដែលផ្តល់ភ័ស្តុតាង
  - ការអានសេចក្តីថ្លែងការពារក្តីលម្អិតទៅកាន់គណៈវិនិច្ឆ័យ និង
  - អនុញ្ញាតឱ្យសួរសំណួរនាំមុខដោយផ្អែកលើសេចក្តីថ្លែងនោះនៅក្នុងការចោទសួរសាក្សី នៅពេលដែលគេឃើញច្បាស់ថាចុងចោទមានការលំបាកក្នុងការរំលឹកអង្គហេតុ។

# ចុងចោទងាយរងគ្រោះ

- *Thomas* [២០២០] EWCA Crim ១១៧ ???
- អន្តរការីមិនគួរត្រូវបានតែងតាំង ដោយគ្រាន់តែជាទម្លាប់នៃការគ្រប់គ្រងនោះទេ ប៉ុន្តែផ្ទុយទៅវិញ ការតែងតាំងត្រូវបានធ្វើឡើងដោយសារមានហេតុផលច្បាស់លាស់សម្រាប់ប្រកាន់យកវិធានការនោះ។ គេគប្បីយល់ឱ្យបានច្បាស់ថាការសម្របសម្រួលផ្សេងទៀតទាំងអស់នៃដំណើរការកាត់ក្តី នឹងបំពេញតាមតម្រូវការរបស់ចុងចោទបានគ្រប់គ្រាន់ទេ ដើម្បីធានាថាពួកគេអាចចូលរួមក្នុងការកាត់ក្តីប្រកបដោយប្រសិទ្ធភាព។ គេគប្បីមានការវាយតម្លៃមិនត្រឹមតែកាលៈទេសៈពាក់ព័ន្ធរបស់ចុងចោទប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងកាលៈទេសៈនៃការកាត់ក្តីដោយឡែកនោះផងដែរ៖ ការលំបាកទាំងឡាយណាដែលចុងចោទជួបប្រទះត្រូវតែត្រូវបានពិចារណាក្នុងបរិបទនៃកិច្ចដំណើរការនីតិវិធីជាក់ស្តែងដែលចុងចោទបានជួបប្រទះ។

# ចុងចោទងាយរងគ្រោះ

- តុលាការយុវជន *TI v Bromley Youth Court* [2020] EWHC 1204 (Admin)
- ខណៈពេលដែលមិនមានមូលដ្ឋានច្បាប់ស្តីពីការដែលអន្តរការីអាចត្រូវបានតែងតាំងដើម្បីជួយចុងចោទ បទបញ្ញាអនុវត្តព្រហ្មទណ្ឌលេខ ៣F.១៣ ចែងថាតុលាការអាចអនុវត្តអំណាចដែលមានស្រាប់របស់ខ្លួនក្នុងការតែងតាំងអន្តរការីដើម្បីជួយដល់ចុងចោទដែលផ្តល់ភ័ស្តុតាង ឬសម្រាប់ការកាត់ក្តីទាំងមូល។ បទបញ្ញាអនុវត្តព្រហ្មទណ្ឌលេខ ៣F.២៥ បានចែងថាមិនមានការសន្មត់ថាចុងចោទដែលមានអាយុក្រោម ១៨ ឆ្នាំ នឹងត្រូវបានជួយដោយអន្តរការីនៅតុលាការនោះទេ ប៉ុន្តែការសម្រេចត្រូវតែធ្វើឡើងដោយផ្អែកលើមូលដ្ឋានបុគ្គលជាក់ស្តែងដោយគិតគូរដល់កាលៈទេសៈនៃករណីនោះ។ ចំណុចសំខាន់គឺថាចុងចោទណាក៏ដោយនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌត្រូវតែទទួលការកាត់ក្តីដោយយុត្តិធម៌។ នៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងជនជាប់ចោទវ័យក្មេងដែលងាយរងគ្រោះ តុលាការត្រូវពិចារណាថាតើបញ្ហានៃការប្រមូលផ្តុំ និងការយល់ដឹងអាចប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការចូលរួមក្នុងការកាត់ក្តីឬទេ។
- កម្មវិធី HMCTS Intermediary Scheme - ចាប់តាំងពីថ្ងៃទី ១ ខែមេសា

# ចុងចោទងាយរងគ្រោះ

- គោលការណ៍ដែលមានចែងក្នុង *Lubemba* អំពីជំហានចាំបាច់ ដើម្បីជួយសម្រួលដល់ការចូលរួមរបស់សាក្សីងាយរងគ្រោះ ត្រូវអនុវត្តដូចគ្នាចំពោះចុងចោទជាកុមារ ក្នុងនាមជាសាក្សី ក៏ដូចជាសាក្សីងាយរងគ្រោះផ្សេងទៀតដែរ៖ *Grant-Murray (Janhelle); McGill (Joseph) [2017] EWCA Crim 1228; [2018] Crim. L.R. 71* (ពិបាកក្នុងការយល់ថាមេធាវីការពារក្ដីមានសមត្ថភាពដើម្បីធ្វើសកម្មភាពក្នុងករណីដែលពាក់ព័ន្ធនឹងសាក្សី ឬចុងចោទវ័យក្មេង លុះត្រាតែមេធាវីការពារក្ដីបានទទួលការបណ្ដុះបណ្ដាលជាក់លាក់)

# ចុងចោទងាយរងគ្រោះ

- សិទ្ធិក្នុងកាត់ក្តីចុងចោទងាយរងគ្រោះ និងមិនងាយរងគ្រោះរួមគ្នា?
- ទស្សនកិច្ចដើម្បីស្គាល់តុលាការសម្រាប់ចុងចោទងាយរងគ្រោះ (ដោយមាន ឬគ្មានអន្តរការី)?
- តើចុងចោទត្រូវអង្គុយនៅទីណា ហើយជាមួយអ្នកណា?
- តើចុងចោទគប្បីត្រូវបានការពារពីបញ្ហាផ្សព្វផ្សាយអ្វីឬទេ?
- ការរឹតបន្តឹងការរាយការណ៍ជាទូទៅ?
- តើចាំបាច់ត្រូវមានសវនាការស្តីពីវិធានដំណើរការនីតិវិធី (GRH) ឬទេ?

# ចុងចោទងាយរងគ្រោះ

- តើតំណាងអយ្យការត្រូវសរសេរសំណួរឬទេ?
- សក់ពាក់ និងអាវវែង (សម្រាប់ចៅក្រម)?
- ដាក់កំហិតលើការចូលរួមពីសាធារណជន?
- ភាសាសមស្របតាមអាយុឬទេ?
- ធ្វើការកែសម្រួលសមរម្យដើម្បីអនុញ្ញាតឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាព

# ចប់

